# វិហារឈើវត្តវិហារគោក

វត្តវិហារគោកមានវិហារបុរាណសង់អំពីឈើ ស្ថិតនៅខាងត្បូងវត្តវិហារសសរ១០០ ក្នុងឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ ដែលអ្នកស្រាវជ្រាវយល់ថាវត្តនេះកសាងនៅលើអតីតតំបន់បូជនីយដ្ឋានប្រវត្តិសាស្ត្រសម្ពុបុរី ជារាជធានីមុនសម័យអង្គរ។[៧] វិហារវត្តនេះមានទីតាំងស្ថិតនៅប្របដងទន្លេមេគង្គ សង់បែរផ្ដោះទៅទិសខាងកើត ក្នុងលំនាំជាសិល្បៈស្ថាបត្យកម្មវិហារជហ្វាបួន ដែលមានហោជាងសងខាងធ្លាក់អំពីឈើ ប្រកបដោយក្បាច់រចនាយ៉ាងល្អវិចិត្រ។ ផ្អែកតាមអក្សរចារឹកលើហោជាងខាងមុខឱ្យដឹងថា វិហារដែលនៅគង់វង្សមកដល់សព្វថ្ងៃនេះ កសាងឡើងក្នុងឆ្នាំឆ្លូវ ពុទ្ធសករាជ២៤៦៨ ពោលគឺកសាងឡើងបានជិត១សតវត្សរកន្លងមកហើយ (ប្រហែលនៅក្នុងរវាងឆ្នាំ១៩២៥) (រូបលេខ២១)។



រូបលេខ២១ វិហារវត្តវិហារគោក (មើលពីទិសឦសាន)

យោងតាមឯកសារលោក *Etienne Aymonier* ផ្សាយក្នុងឆ្នាំ១៩០០ ហៅបូជនីយដ្ឋាននេះថា "ប្រាសាទគុក ឬវត្តវិហារគុក ឬទួលគុកវិហារ" ដែលជាអតីតទីតាំងបុរាណដ្ឋាន

[៧] *Adémard Leclère 1914: 39*

កសាងក្នុងរវាងសតវត្សទី៦ ឬទី៧ នៃគ្រិស្តសករាជ ហើយមានសិលាចារឹកភាសាសំស្ក្រឹតមួយផ្ទាំងតម្កល់នៅសារមន្ទីរហ្គីមេត៍ប្រទេសបារាំង។ ក្នុងឯកសារនេះដែរ លោក *Aymonier* បានសរសេរឈ្មោះខាងលើជាឡាតាំងថា *"Prasat Kouk, Vat Prahéar Kouk ou Tuol Kouk"*។[២] ពាក់ព័ន្ធនឹងបុរាណដ្ឋានដដែល នៅក្នុងឆ្នាំ១៩០២ លោក *Étienne Lunet de Lajonquière* បានសរសេរ *"Vat Praḥ Vihear Kuk"*[៣] យ៉ាងដូច្នេះ ដែលនាំឱ្យយើងសង្កេតឃើញថាក្នុងសំណេរចាស់ហៅ "វិហារគុក" ហើយសព្វថ្ងៃក្លាយមកជា "វិហារគោក"។ តាមរយៈឯកសារទាំងពីរខាងលើនេះ យើងអាចពិចារណាបានថា មុនមានវិហារសព្វថ្ងៃ (រូបលេខ២-៤) វត្តវិហារគុក ឬវិហារគោក អាចមានវិហារ ឬសាទ្បុំចាស់សម្រាប់ប្រើប្រាស់ក្នុងកិច្ចនានាតាមគន្លងពុទ្ធសាសនាម្តងរួចមកហើយ។



រូបលេខ២ វិហារវត្តវិហារគោក មើលពីក្រោយ



រូបលេខ៣ វិហារវត្តវិហារគោក មើលពីទិសពាយ័ព្យ



រូបលេខ៤ វិហារវត្តវិហារគោក មើលពីចំហៀង

ផ្អែកតាមសារបានសង្ខេបនៃអារាមវត្តវិហារគោកឱ្យដឹងថា ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ វិហារនេះត្រូវបានគេយកអាចម៍ក្របីទៅលាបលុបបំផ្លាញគំនូរបុរាណចោលបណ្តាលឱ្យខូចខាតស្ទើរទាំងស្រុង។ មុនឆ្នាំ១៩៩៨ បរិវេណវត្តនេះ បានប្រែក្លាយជាបន្ទាយទាហានមួយរយៈ។ ប៉ុន្តែក្រោយពីនោះមកគេដឹងថាវិហារវត្តវិហារគោក ធ្លាប់បានជួសជុល និងកែសម្រួលរចនាសម្ព័ន្ធខ្លះៗម្តងជាពីរដងរួចមកហើយ តែទម្រង់ទូទៅនៃវិហារនៅរក្សាតាមលំនាំដើម ពោលគឺជាទម្រង់វិហារជហ្វាបួន ប្រក់ក្បឿងស្រកាលេញដំបូលជ្រាលបីថ្នាក់ ទ្រដោយសសរឈើ៦០ ដើម ជញ្ជាំងរៀបឥដ្ឋ បូកកំបោរបាយអរ។

---

[២] *Etienne Aymonier 1900: 303*

[៣] *Étienne Lunet de Lajonquière 1902: 187*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ក្នុងឆ្នាំ២០០៥ វិហារវត្តវិហារគោកបានជួសជុលកែលម្អម្តងទៀត និងបានប្តូរសសររបៀងជុំវិញទាំង២៨ដើម ព្រមទាំងប្តូរការ៉ូផងដែរ (រូបលេខ២៥)។



រូបលេខ២៥ សសរឈើជុំវិញរបៀងវិហារដែលប្តូរថ្មីក្នុងឆ្នាំ២០០៥

ដោយឡែកចំពោះរចនាសម្ព័ន្ធ និងការលម្អផ្នែកដំបូល យើងមើលឃើញថានៅផ្នែកខាងមុខ គេបំពាក់ជហ្វា២ ផ្នែកខាងក្រោយបំពាក់ជហ្វា២ ហើយហោជាងខាងមុខឆ្លាក់ក្បាច់ភ្ញីទេសយ៉ាងរស់រវើក រំលេចដោយឆ័ត្ររួត អមសងខាងផ្ចិតយស និងផ្ទាំងចារឹកមួយឃ្លាថា "ព្រះពុទ្ធសក្ខរាជព្រះសាស្នា២៤៦៨ព្រះវស្សា ឆ្នាំឆ្លូវសប្តសក្ស ព្រះអរ្ប៉ូនិគម (សុក)" (រូបលេខ២៦)។ រីឯហោជាងខាងក្រោយ គេបានរចនាលម្អដោយក្បាច់ភ្ញីទេសក្នុងទម្រង់ប្រហាក់ប្រហែលនឹងហោជាងខាងមុខ ព្រមទាំងឆ្លាក់រំលេចដោយឆ័ត្ររួតអមសងខាងតួអង្គអង្គុទ (?) ដែលអង្គុយនៅលើបល័ង្ក ដៃស្តាំកាន់ព្រះខាន់ ដៃឆ្វេងកាន់ទង់ ក្រោម ឆ័ត្ររួតបីជាន់នៅកណ្តាលផ្ទៃហោងជាង (រូបលេខ២៧)។





រូបលេខ៦ ហោជាងខាងមុខ (ខាងកើត) រូបលេខ៧ ហោជាងខាងក្រោយ (ខាងលិច)

រចនាសម្ព័ន្ធ និងការលម្អផ្ទៃជញ្ជាំងជុំវិញនៃផ្នែកខាងក្រៅវិហារ គេឃើញមានទ្វារចេញចូលនៅផ្នែកខាងមុខចំនួនពី នៅផ្នែកខាងក្រោយចំនួនពីរ និងចំហៀងខាងជើងចំនួនមួយ (ជញ្ជាំងចំហៀងខាងត្បូងពុំមានទ្វារឡើយ) ព្រមទាំងមានបង្អួចជុំវិញវិញចំនួន ១៥។ ក្បាច់លម្អស៊ុមបង្អួចនឹងទ្វារទាំងនេះ គេបានរចនាដោយក្បាច់ពុម្ពស៊ីម៉ងត៍ ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នា (រូបល ៨)។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់ គេឃើញមានរូបព្រះវិស្ណុដៃបួន (?) ឈរលើបល័ង្ក ដៃពីរខាងលើកាន់ត្រីសូល៍ ដៃពីរខាងក្រោមច្រត់ជង្គង់។ រីឯនៅតាមរង្វង់ក្បាច់អមសងខាងបល័ង្កនោះ គេឃើញមានក្បាលមនុស្ស (?) ចំនួនពីរពាក់មកុដ (រូបលេខ៩)។





រូបលេខ៨ ការលម្អទ្វារ-បង្អួច (ផ្នែកខាងជើង) រូបលេខ៩ ក្បាច់លម្អលើទ្វារ

ផ្នែកខាងក្នុងនៃវិហារ គេឃើញមានសសរឈើពីរជួរ សរុបចំនួន១២ ដើម រត់ត្រង់អមសងខាងល្វែងគ្រឹះ ទ្រពិតាន និងគ្រឿងបង្គុំឈើនៅផ្នែកខាងលើ (រូបលេខ១០-១២)។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ប៉ុន្តែសសរទាំងអស់ និងគ្រឿងបង្គុំឈើនានានៅផ្នែកខាងក្នុងនេះ យើងពុំឃើញមានការលម្អដោយក្បាច់រចនា ឬគំនូរបុក ឬទឹបទឹកមាសឡើយ។ ចំពោះព្រះដីរ៍ និងបល័ង្ក គេបានជួសជុល កែលម្អ និងលាបពណ៌ថ្មីក្នុងឆ្នាំ២០១៥។ ការរចនាលាបពណ៌ថ្មីនៅលើបល័ង្ក និងព្រះដីរ៍នេះ គេសង្កេតឃើញប្រើតែពណ៌ទឹកមាសតែម្យ៉ាងគត់ ឥតមានពណ៌ផ្សេងទេ។ នៅលើព្រះដីរ៍ គេចងលម្អដោយឆ័ត្រត្រួតប្រាំជាន់ភ្ជាប់ចេញពីពិតានឈើ។ ពិតានឈើលើព្រះដីរ៍នេះសោត គេរក្សាសភាពឈើដដែល ពុំមានគូរ ឬរចនាលម្អអ្វីឡើយ។



រូបលេខ១០ ព្រះដីរ៍ និងបល័ង្កក្នុងវិហារវត្តវិហារគោក

KHMER CIVILIZATION





រូបលេខ១១-១២ រចនាសម្ព័ន្ធ និងគ្រឿងបង្គុំឈើនានានៅផ្នែកខាងក្នុងវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដូចបានបញ្ជាក់មកខាងដើមបន្តិចស្រេចថា គំនូរដើមនៃវិហារនេះបានបំផ្លិចផ្លាញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ រីឯគំនូរលម្អលើផ្ទៃជញ្ជាំងផ្នែកខាងក្នុង និងលើពិតានសព្វថ្ងៃ គូរនៅក្នុងឆ្នាំ២០០៨។ ប្រធានបទគំនូរទាំងនេះ ពុំខុសអ្វីពីគំនូរតាមវិហារថ្មីៗ ដែលកសាងក្នុងសម័យបច្ចុប្បន្នឡើយ។ នៅលើផ្ទៃពិតានមានគំនូរ៦ផ្ទាំង និយាយអំពីព្រះច័ន្ទ្រ ព្រះអាទិត្យ ព្រះប្រាំព្រះអង្គ និងអន្ទើផ្សេងទៀតក្នុងពុទ្ធប្រវត្តិដូចបណ្តាវិហារផ្សេងដែរ (រូបលេខ១៣)។ ទន្ទឹមនឹងនេះ គំនូរនៅលើជញ្ជាំង យើងសង្កេតឃើញមានពីរជួរលើក្រោម។ ជួរលើផ្តើមចេញពីត្រង់ព្រះអង្គបរិនិព្វាននៅលើជញ្ជាំងខាងមុខឈមនឹងព្រះជីវ៍ និងផ្ទាំងជាបន្តបន្ទាប់មកទៀតមានដូចជា ព្រះអង្គទ្រង់ប្រសូត សម្តែងឫទ្ធិ រៀបអភិសេក ចេញបួស ធ្វើទុក្ខកិរិយា ត្រាស់ដឹង ផ្ចាញ់មារ ប្រោសពុទ្ធមាតា ប្រោសពុទ្ធបិតា... ហូរហែតាមលំដាប់ពុទ្ធប្រវត្តិ រហូតដល់ព្រះអង្គទ្រង់ប្រឈួន និងបរិនិព្វាន (រូបលេខ១៤-១៥)។ ចំណែកជួរខាងក្រោម គឺជាអន្ទើនានាក្នុងទសជាតក។



រូបលេខ១៣ គំនូរលើពិតាននៃវិហារវត្តវិហារគោក

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ១៨-១៩ ផ្នែកខ្លះនៃគំនូរពុទ្ធប្រវត្តិលើផ្ទៃជញ្ជាំងក្នុងវិហារ

ដូច្នេះសរុបមក វិហារវត្តវិហារគោកមានអាយុកាលជិត១០០ឆ្នាំ ជាបូជនីយដ្ឋានពុទ្ធសាសនា ដែលបានកសាងឡើងនៅលើបុរាណដ្ឋានមុនសម័យអង្គរ ហើយបានជួសជុល កែលម្អ ថែទាំជាបន្តបន្ទាប់រហូតមកគង់វង្សដល់សព្វថ្ងៃ។ ប៉ុន្តែរចនាសម្ព័ន្ធសំណង់ឈើក្នុងលំនាំស្ថាបត្យកម្មប្រហាក់ប្រហែលនេះ គេសង្កេតឃើញថានៅមានសេសសល់ពុំច្រើនឡើយរហូតមកដល់បច្ចុប្បន្ន។ ប៉ុន្តែមុនមានវិហារសព្វថ្ងៃ គេយល់ថាប្រហែលមានសំណង់វិហារចាស់ ឬសាឡាំចាស់សាងសង់ឡើងម្តងរួចមកហើយ ដ្បិតសំណេររបស់ Etienne Aymonier និង Étienne Lunet de Lajonquière សុទ្ធតែបានពណ៌នាអំពីបូជនីយដ្ឋាននេះ។

## ឯកសារយោង

Adémard Leclère

1914, *Histoire du Cambodge,* Librairie Paul Geuthner, Paris

Etienne Aymonier

1900, *Le Cambodge; Le Royaume Actuel, Tome I,* Ernest Leroux, Paris

Étienne Lunet de Lajonquière

1902, *Inventaire Descriptif des Monuments du Cambodge, Tome I,* Ernest Leroux, Paris

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត